**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៤៩៩ ......សហវ.ប្រក.២០២៣

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការបែងចែកចំណូលពីការពិន័យចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០២០ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៣៩ និងមាត្រា១៤៤ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១០ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៨៧ ចំណងជើងចំណុច "គ" ផ្នែកទី៣ នៃជំពូកទី៤ មាត្រា៨៩ មាត្រា៩០ មាត្រា៩១ មាត្រា៩៤ មាត្រា១១០ មាត្រា១២០ និងមាត្រា១២២ នៃច្បាប់ស្តីពីការងារ ដែលត្រូវប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១២៣ មាត្រា១៣៨ មាត្រា១៦២ មាត្រា៣០០ មាត្រា៣៤៣ មាត្រា៣៥០ មាត្រា៣៦៣ និងមាត្រា៣៦៧ នៃច្បាប់ស្តីពីការងារ ដែលត្រូវប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញប្រកាសអន្តរក្រសួងលេខ៣២៦/២២ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីប្រាក់ឈ្នួលយោងប្រចាំថ្ងៃ
- បានឃើញសេចក្តីសម្រេចលេខ២៥ សសរ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ របស់រាជរដ្ឋាភិបាល ស្តីពីការបង់ភាគទានរបស់ក្រសួង ស្ថាប័ន ចូលក្នុងមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសអន្តរក្រសួងលេខ.[illegible]... សហវ.ប្រក.អទច ចុះថ្ងៃទី...៣១... ខែ[illegible]. ឆ្នាំ២០២៣ ស្តីពីការផាកពិន័យចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញសារាចរលេខ០០៦ សហវ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ស្តីពីនីតិវិធី និងកិច្ចបញ្ជិកានៃការអនុវត្តចំណូលពីកម្រៃសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងចំណូលពីកម្រៃសេវានិងចំណូលពីការពិន័យជាប្រាក់ដែលប្រមូលនៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

ចំណូលពីការពិន័យចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលប្រមូលបានដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានបែងចែកដូចខាងក្រោម ÷

**ក. ការបែងចែកចំណូលដែលប្រមូលបានដោយរដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ក.១- ចំណូលពីការផាកពិន័យ**

១- បង់ចូលថវិកាជាតិ ចំនួន ៣០% នៃចំណូលប្រមូលបាន

២- ប្រាក់រង្វាន់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ៦៩% នៃចំណូលប្រមូលបាន ត្រូវបានកំណត់ដូចតទៅ ÷

- បង់ភាគទានចូលមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចំនួន ១០% នៃ ៦៩%
- ប្រើប្រាស់នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ៩០% នៃ ៦៩%

៣- ប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំនួន ១% នៃចំណូលប្រមូលបាន។

**ក.២- ចំណូលពីការផ្តន្ទាទោសពិន័យជាប្រាក់ ដោយអនុវត្តតាមសេចក្តីសម្រេចរបស់សាលាជម្រះក្តី**

១- បង់ចូលថវិកាជាតិ ចំនួន ២៦% នៃចំណូលប្រមូលបាន

២- ប្រាក់រង្វាន់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ៤៩% នៃចំណូលប្រមូលបាន ត្រូវបានកំណត់ដូចតទៅ ÷

- បង់ភាគទានចូលមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចំនួន ១០% នៃ ៤៩%
- ប្រើប្រាស់នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ៩០% នៃ ៤៩%

៣- ប្រាក់រង្វាន់សរុបរបស់សាលាជម្រះក្តីពាក់ព័ន្ធ ចំនួន ២៤% នៃចំណូលប្រមូលបាន

៤- ប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំនួន ១% នៃចំណូលប្រមូលបាន។

**ខ. ការបែងចែកចំណូលដែលប្រមូលបានដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត**

**ខ.១- ចំណូលពីការផាកពិន័យ**

១- បង់ចូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត ចំនួន ៣០% នៃចំណូលប្រមូលបាន

២- ប្រាក់រង្វាន់របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្តចំនួន ៦៩% នៃចំណូលប្រមូលបាន

៣- ប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ចំនួន ១% នៃចំណូលប្រមូលបាន។

ខ.២- ចំណូលពីការផ្តន្ទាទោសពិន័យជាប្រាក់ ដោយអនុវត្តតាមសេចក្តីសម្រេចរបស់សាលាជម្រះក្តី

១- បង់ចូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត ចំនួន ២៦% នៃចំណូលប្រមូលបាន

២- ប្រាក់រង្វាន់របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្តចំនួន ៤៩% នៃចំណូលប្រមូលបាន

៣- ប្រាក់រង្វាន់សរុបរបស់សាលាជម្រះក្តីពាក់ព័ន្ធ ចំនួន ២៤% នៃចំណូលប្រមូលបាន

៤- ប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ចំនួន ១% នៃចំណូលប្រមូលបាន។

**ប្រការ២ .–**

អនុញ្ញាតឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត បុរេប្រទានប្រាក់រង្វាន់សរុបដែលបានកំណត់ក្នុងប្រការ១ នៃប្រកាសអន្តរក្រសួងនេះ ដោយដកយកពីចំណូលប្រមូលបាន និងបើកផ្តល់ចំណែកប្រាក់រង្វាន់ជូនដល់អង្គភាពគោលដៅនីមួយៗ។

**ប្រការ៣ .–**

ជារៀងរាល់ខែ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវធ្វើការទូទាត់ប្រាក់រង្វាន់ដែលបានបុរេប្រទានតាមការកំណត់ក្នុងប្រការ២ នៃប្រកាសអន្តរក្រសួងនេះ ដោយអនុវត្តតាមនីតិវិធីដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជារៀងរាល់ខែ រដ្ឋបាលរាជធានី ខេត្ត ត្រូវធ្វើការទូទាត់ប្រាក់រង្វាន់ដែលមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត បានបុរេប្រទានតាមការកំណត់ក្នុងប្រការ២ នៃប្រកាសអន្តរក្រសួងនេះ ដោយអនុវត្តតាមនីតិវិធីដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៤ .–**

ការផ្តល់ប្រាក់រង្វាន់ ដែលមានចែងក្នុងប្រកាសអន្តរក្រសួងនេះ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់ការចំណាយឧបត្ថម្ភជូនមន្ត្រីរាជការដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត និងប្រើប្រាស់សម្រាប់ការចំណាយពង្រឹងយន្តការប្រមូលចំណូល។

ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៥ កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៦"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ